

# កម្មវិធីភាសាអង់គ្លេសជាភាសាទី ២ (ESL)

## *តើកម្មវិធីភាសាអង់គ្លេសជាភាសាទី ២ (ESL) មានន័យយ៉ាងណា ?*

អ៊ីអេសអិល គឺជាកម្មវិធីមួយ ដែលត្រូវបានរៀបចំឡើង សម្រាប់មនុស្សពេញវ័យ (ចាប់ពីអាយុ ១៨ ឆ្នាំឡើង) ដែលមិននិយាយភាសាអង់គ្លេស ពីកំណើត ។ កម្មវិធីនេះ យកចិត្តទុកដាក់លើ ចំណុចសំខាន់ ៤ នៃសមត្ថភាពខាងភាសា ពោលគឺ ការអាន, ការសរសេរ, ការនិយាយ, និង ការស្តាប់ ។ ថ្នាក់នីមួយៗ មានចំនួនសិស្សតិចនាក់ និង មានកម្មវិធីជំនួយការរៀនតាមកុំព្យូទ័រផងដែរ ។

## *តើនរណាខ្លះមានសិទ្ធិចូលរៀនក្នុងកម្មវិធីនេះ ?*

ជនណាមានអាយុ ១៩ ឆ្នាំឡើង ដែលជាជនអន្តោប្រវេសន៍ ឬ ជនភៀសខ្លួន មានសិទ្ធិរស់នៅស្របច្បាប់ ។ ជនណា ដែលស្នាក់នៅដោយសារទិដ្ឋាការនិស្សិត ឬ អ្នកទេសចរណ៍ មិនមានសិទ្ធិចូលរួមក្នុងកម្មវិធីនេះទេ ។

## *តើត្រូវបង់ថ្លៃប៉ុន្មាន សម្រាប់ចុះឈ្មោះចូលរៀនកម្មវិធី នេះ ?*

ថ្លៃចុះឈ្មោះចូលរៀន គឺ $25 សម្រាប់កម្មវិធីរយៈពេល ១ ត្រីមាស (ប្រហែល ១១ សប្តាហ៍) ។ យើងមានការលើកលែង មិនយកថ្លៃសាលា សម្រាប់និស្សិតដែលពិបាករកប្រាក់បង់សាលា ។

## *តើថ្នាក់រៀនចាប់ផ្តើមពេលណា ?*

ថ្នាក់រៀនពេលថ្ងៃ និង ពេលយប់ បើករៀនចាប់ពីថ្ងៃ ចន្ទ រហូតដល់ថ្ងៃ ព្រហស្បតិ៍ ។ និស្សិតអាចផ្លាស់ប្តូររវាងថ្នាក់រៀនពេលថ្ងៃ និង ថ្នាក់រៀនពេលយប់ បើមានបញ្ហាទាស់ជាមួយនឹងកាលវិភាគនៅកន្លែងធ្វើការ ឬកាលវិភាគប្រចាំខ្លួន ។

## *តើខ្ញុំត្រូវចាប់ផ្តើមរបៀបណា ?*

និស្សិតថ្មីត្រូវចូលរៀនថ្នាក់ត្រៀម ***មេរៀនជោគជ័យសម្រាប់និស្សិត*** (Student Success) ដែលមានរយៈពេល ៤ ថ្ងៃ មុនពេលអាចចុះឈ្មោះចូលរៀនថ្នាក់ អ៊ីអេសអិល ។ សូមទូរសព្ទ ឬអញ្ជើញមកការិយាល័យអប់រំមូលដ្ឋានសម្រាប់មនុស្សចាស់ (Adult Basic Education) ដើម្បីសួរព័ត៌មានអំពីថ្ងៃចុះឈ្មោះចូលរៀនថ្នាក់ត្រៀម Student Success ។


**<u>អាសយដ្ឋាន</u>**

CPTC Bldg. 37
4500 Steilacoom Blvd. S.W.
Lakewood, WA 98499
(253) 589-5702


## សំណួរ-ចម្លើយ

ស: តើអ្នកទេសចរណ៍ មកពីប្រទេសក្រៅ អាចចូលរួម កម្មវិធី នេះបានទេ ?

ឆ: ទេ ។ កម្មវិធីនេះ ត្រូវបានរៀបចំ សម្រាប់ផ្តល់សេវាដល់ អ្នកមានសិទ្ធិ រស់នៅប្រទេសអាមេរិក ប៉ុណ្ណោះ ។

ស: តើជំនួយហិរញ្ញវត្ថុ រាប់បញ្ចូលទាំងប្រាក់សម្រាប់បង់ថ្លៃថ្នាក់ ESL ឬទេ ?

ឆ: ទេ, ប៉ុន្តែ និស្សិត ដែលមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុ អាចត្រូវបានលើកលែងមិនបង់ប្រាក់ សម្រាប់កម្មវិធីនេះ ។

ស: ពេលណា ទើបថ្នាក់ចាប់ផ្តើម ?

ឆ: នៅថ្ងៃចូលរៀន នៃត្រីមាសនីមួយ ៗ ប៉ុន្តែ និស្សិតថ្មី ត្រូវចូលរៀន ថ្នាក់ត្រៀម (Student Success) ដើម្បីមានសិទ្ធិចុះឈ្មោះ ។ សូមទូរសព្ទសួររកព័ត៌មាន នៃថ្ងៃចុះឈ្មោះរៀនថ្នាក់ត្រៀម Student Success ដែលបើកនៅវគ្គក្រោយ ។




CLOVER PARK
TECHNICAL COLLEGE
Excellence. Experience. Employment.


**Clover Park Technical College** មិនរើសអើងបុគ្គលណាម្នាក់ដោយសារតែពូជសាសន៍, ពណ៌សម្បុរ, ជាតិកំណើតដើម, ភេទ, ពិការភាព, និន្នាការផ្លូវភេទ, ឬអាយុ នៅក្នុងកម្មវិធី និង សកម្មភាពនានារបស់ខ្លួនឡើយ ។